**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ: ០១៣/២០ គ.ម.ក./ប្រ.ក.

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌតម្រូវលើភាពរឹងមាំហិរញ្ញវត្ថុ នៃក្រុមហ៊ុនសមាគមីគណ្ណាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០០៤/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ

- បានឃើញប្រកាសលេខ ០០៥/២០ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ស្តីពីវិសោធនកម្ម លើប្រកាសលេខ ០០៤/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងកំណត់ពីលក្ខខណ្ឌ និងនីតិវិធីក្នុងការត្រួតពិនិត្យលើភាពរឹងមាំហិរញ្ញវត្ថុ និងកំណត់ពីកាតព្វកិច្ចផ្សេងៗរបស់ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីអគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទ ឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ។

### ប្រការ ២.- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

### ប្រការ ៣.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ព្រមទាំងមានក្នុងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ។

**ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត** សំដៅដល់ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

**កម្រិតមូលធនសុទ្ធកាតព្វកិច្ច** (Prescribed Level of Net Capital) សំដៅដល់កម្រិតអប្បបរមានៃមូលធនសុទ្ធដែលក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវគណនាអនុលោមតាមប្រការ ១៧ នៃប្រកាសនេះ។

**ការតម្រូវពង្រឹងការគ្រប់គ្រង** (Management Improvement Requirement) សំដៅដល់ការតម្រូវ

ឱ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ពង្រឹងការគ្រប់គ្រងនៅពេលអនុបាតមូលធនសុទ្ធរបស់ក្រុមហ៊ុននោះ ធ្លាក់ក្រោម ១២០ (មួយរយម្ភៃ) ភាគរយ ដូចមានចែងនៅក្នុងប្រការ ២៥ នៃប្រកាសនេះ។

**ការបញ្ជាពង្រឹងការគ្រប់គ្រង** (Management Improvement Order) សំដៅដល់ការបញ្ជាឱ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ពង្រឹងការគ្រប់គ្រងនៅពេលអនុបាតមូលធនសុទ្ធរបស់ក្រុមហ៊ុននោះ ធ្លាក់ក្រោម ១០០ (មួយរយ) ភាគរយ ដូចមានចែងនៅក្នុងប្រការ ២៦ នៃប្រកាសនេះ។

**មូលធនភាគហ៊ុនិក** (Shareholders' Equity) សំដៅដល់ទ្រព្យសកម្មដែលនៅសល់ចុងក្រោយ បន្ទាប់ពីបានដកបំណុលទាំងអស់ចេញពីទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

**លក្ខខណ្ឌចាប់បង្ខំសងរួម** (Cross Default) សំដៅដល់លក្ខខណ្ឌក្នុងកិច្ចសន្យាផ្តល់កម្ចីដែលការពារផលប្រយោជន៍ឥណទាយក ដោយចែងពីករណីកូនបំណុលខកខានមិនបានបំពេញកាតព្វកិច្ចស្របតាមកិច្ចសន្យាផ្តល់កម្ចីណាមួយ ធ្វើឱ្យកើតឡើងនូវការខកខានមិនបានបំពេញកាតព្វកិច្ចលើបំណុលផ្សេងទៀតដោយស្វ័យប្រវត្តិ។

**លក្ខខណ្ឌហាមឃាត់ការខ្ចីប្រាក់បន្ថែម** (Negative Pledge) សំដៅដល់លក្ខខណ្ឌក្នុងកិច្ចសន្យាផ្តល់កម្ចី ដែលហាមឃាត់កូនបំណុលមិនឱ្យខ្ចីបំណុលបន្ថែមដោយគ្មានការយល់ព្រមពីឥណទាយក។

**អនុក្រឹត្យ** សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**អនុបាតមូលធនសុទ្ធ** (Net Capital Ratio) សំដៅដល់ផលធៀបរវាងមូលធនសុទ្ធ និងកម្រិតមូលធនសុទ្ធកាតព្វកិច្ច។

**អនុសាសន៍ពង្រឹងការគ្រប់គ្រង** (Management Improvement Recommendation) សំដៅដល់ការផ្តល់អនុសាសន៍ដល់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ឱ្យពង្រឹងការគ្រប់គ្រងនៅពេលអនុបាតមូលធនសុទ្ធរបស់ក្រុមហ៊ុននោះ ធ្លាក់ក្រោម ១៥០ (មួយរយហាសិប) ភាគរយ ដូចមានចែងនៅក្នុងប្រការ ២៤ នៃប្រកាសនេះ។

**ឥណទេយ្យមិនមែនពាណិជ្ជកម្ម** (Non-Trading Receivables) សំដៅដល់សាច់ប្រាក់ដទៃទៀតដែលអតិថិជនជំពាក់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតក្រៅពីឥណទេយ្យពាណិជ្ជកម្ម។

**ឥណទេយ្យពាណិជ្ជកម្ម** (Trading Receivables) សំដៅដល់សាច់ប្រាក់ដែលអតិថិជនជំពាក់សម្រាប់ប្រតិបត្តិការបញ្ជាទិញរបស់អតិថិជនដែលរួមទាំងកម្រៃជើងសា។

## ជំពូកទី ២

## លក្ខខណ្ឌតម្រូវលើមូលធនភាគហ៊ុនិក

### ប្រការ ៤.- ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ និងត្រូវគណនាអនុបាតមូលធនសុទ្ធដោយអនុលោមតាមប្រកាសនេះ។

**ប្រការ ៥.- កាតព្វកិច្ចរក្សាមូលធនភាគហ៊ុនិក**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ត្រូវរក្សាមូលធនភាគហ៊ុនិកគ្រប់ពេលវេលាមិនឱ្យតិចជាងលក្ខខណ្ឌតម្រូវលើមូលធនអប្បបរមាដែលបានកំណត់ក្នុងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ និងប្រកាសស្តីពីវិសោធនកម្មលើប្រកាសលេខ ០០៤/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ។

**ប្រការ ៦.- ប្រាក់តម្កល់ធានាអាជីវកម្ម**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ត្រូវរក្សាឱ្យបានគ្រប់ពេលវេលានូវប្រាក់តម្កល់ធានាអាជីវកម្មដែលបានកំណត់ក្នុងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ និងប្រកាសស្តីពីវិសោធនកម្មលើប្រកាសលេខ ០០៤/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត មិនត្រូវប្រើប្រាស់ប្រាក់តម្កល់ធានាអាជីវកម្មដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ធ្វើជាការធានាផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្ម លើកលែងតែការដកសម្រាប់ប្រើប្រាស់ក្នុងគោលបំណងដូចមានកំណត់ក្នុងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណនិងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ និងមានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៧.- កាតព្វកិច្ចជូនដំណឹង**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ត្រូវជូនដំណឹងភ្លាមមក **គ.ម.ក.** ក្នុងករណីក្រុមហ៊ុនមិនអាចបំពេញ ឬដឹងថាមិនអាចបំពេញកាតព្វកិច្ចដូចមានចែងក្នុងប្រការ ៥, ប្រការ ៦ និងកថាខណ្ឌទី ២ នៃប្រការ ៨ នៃប្រកាសនេះ។

## ជំពូកទី ៣

## លក្ខខណ្ឌតម្រូវលើអនុបាតមូលធនសុទ្ធ

**ប្រការ ៨.- អនុបាតមូលធនសុទ្ធ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ត្រូវគណនាអនុបាតមូលធនសុទ្ធតាមរូបមន្តដូចខាងក្រោម÷

អនុបាតមូលធនសុទ្ធ = មូលធនសុទ្ធ ÷ កម្រិតមូលធនសុទ្ធកាតព្វកិច្ច

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ត្រូវរក្សាអនុបាតមូលធនសុទ្ធរបស់ខ្លួនមិនឱ្យទាបជាង ១៥០ (មួយរយហាសិប) ភាគរយ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត មិនត្រូវធ្វើប្រតិបត្តិការណាមួយដែលអាចបណ្តាលឱ្យក្រុមហ៊ុនមិនអាចបន្តបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងកថាខណ្ឌទី ២ នៃប្រការនេះ។

## ជំពូកទី ៤

## លក្ខខណ្ឌតម្រូវលើមូលធនសុទ្ធ

### ប្រការ ៩.- ការគណនាមូលធនសុទ្ធ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ត្រូវគណនាមូលធនសុទ្ធតាមរូបមន្តដូចខាងក្រោម÷

មូលធនសុទ្ធ (Net Capital) = ទ្រព្យសកម្មរយៈពេលខ្លីសរុប (Total Current Assets) - បំណុលសរុប (Total Liabilities)

### ប្រការ ១០.- ទ្រព្យសកម្មរយៈពេលខ្លី

ទ្រព្យសកម្មរយៈពេលខ្លីស្របតាមប្រកាសនេះរួមមាន÷

១- សាច់ប្រាក់ និងទ្រព្យសកម្មទាំងអស់ស្របតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ដែលអាចបំលែងជាសាច់ប្រាក់បានក្នុងរយៈពេល ២ (ពីរ) សប្តាហ៍។

២- ប្រាក់តម្កល់ធានាអាជីវកម្មដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការ ៦ នៃប្រកាសនេះ។

៣- មូលបត្រកាន់កាប់ដោយក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ដែលបានបំពេញលក្ខខណ្ឌ និងត្រូវបានវាយតម្លៃស្របតាមប្រការ ១១ នៃប្រកាសនេះ។

៤- ទ្រព្យសកម្មផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

ទ្រព្យសកម្មដែលមិនត្រូវបានចាត់ចូលជាទ្រព្យសកម្មរយៈពេលខ្លីស្របតាមប្រកាសនេះរួមមាន÷

១- កម្ចីដែលផ្តល់ឱ្យ ឬគណនីឥណទេយ្យដែលនឹងទទួលពី ភាគហ៊ុនិក ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ បុគ្គលិកជាន់ខ្ពស់ និយោជិត និងបុគ្គលមានទំនាក់ទំនងពិសេសរបស់ពួកគេ និងបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត។

២- ទ្រព្យអរូបិយ (Intangible Assets)។

៣- ចំណែកនៃបំណុលដែលអតិថិជនម្នាក់ជំពាក់លើសពី ១០ (ដប់) ភាគរយនៃទ្រព្យសកម្មរយៈពេលខ្លីសរុប។

៤- ឥណទេយ្យពាណិជ្ជកម្មដែលមានរយៈពេលលើសពី ៥ (ប្រាំ) ថ្ងៃនៃថ្ងៃជួញដូរ លើកលែងតែមានការអនុញ្ញាតផ្សេងពីនេះដោយ **គ.ម.ក.**។

៥- ឥណទេយ្យមិនមែនពាណិជ្ជកម្មដែលមានរយៈពេលលើសពី ៣ (បី) ខែ។

៦- ទ្រព្យសកម្មផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

**ប្រការ ១១.- ការរាប់បញ្ចូលមូលបត្រជាទ្រព្យសកម្មរយៈពេលខ្លី**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ ការអនុញ្ញាត អាចរាប់បញ្ចូលមូលបត្រដែលបានកាន់កាប់ ជាទ្រព្យសកម្មរយៈពេលខ្លីបាន និងត្រូវវាយតម្លៃដូចខាងក្រោម÷

១- មូលបត្រកម្មសិទ្ធិដែលនឹងត្រូវចុះបញ្ជីនៅទីផ្សារមូលបត្រប្រតិស្រុតនៅព្រះរាជាណាចក្រកម្ពុជា ដែលក្រុមហ៊ុនបានធ្វើបរិវិសកម្ម ត្រូវវាយតម្លៃមិនលើសពី ៧០ (ចិតសិប) ភាគរយនៃថ្លៃធ្វើបរិវិសកម្ម។

២- មូលបត្រកម្មសិទ្ធិដែលបានចុះបញ្ជី និងត្រូវបានជួញដូរដោយជោគជ័យក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃចុងក្រោយនៃថ្ងៃជួញដូរនៅក្នុងទីផ្សារមូលបត្រប្រតិស្រុតនៅព្រះរាជាណាចក្រកម្ពុជា ត្រូវវាយតម្លៃមិនលើសពី ៨០ (ប៉ែតសិប) ភាគរយនៃថ្លៃទីផ្សារបច្ចុប្បន្នរបស់មូលបត្រកម្មសិទ្ធិនោះ។

៣- មូលបត្របំណុលដែលនឹងត្រូវចុះបញ្ជីនៅទីផ្សារមូលបត្រប្រតិស្រុតនៅព្រះរាជាណាចក្រកម្ពុជា ដែលក្រុមហ៊ុនបានធ្វើបរិវិសកម្ម ត្រូវវាយតម្លៃមិនលើសពី ៦០ (ហុកសិប) ភាគរយនៃថ្លៃធ្វើបរិវិសកម្ម។

៤- មូលបត្របំណុលដែលបានចុះបញ្ជី និងត្រូវបានជួញដូរដោយជោគជ័យក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃចុងក្រោយនៃថ្ងៃជួញដូរនៅក្នុងទីផ្សារមូលបត្រប្រតិស្រុតនៅព្រះរាជាណាចក្រកម្ពុជា ត្រូវវាយតម្លៃមិនលើសពី ៧០ (ចិតសិប) ភាគរយនៃថ្លៃទីផ្សារបច្ចុប្បន្នរបស់មូលបត្របំណុលនោះ។

៥- សញ្ញាបណ្ណដែលត្រូវបានចាត់ថ្នាក់ជាកម្រិតវិនិយោគ (Investment Grade Bond) និងសញ្ញាបណ្ណដែលធានាដោយរាជរដ្ឋាភិបាលកម្ពុជា ត្រូវវាយតម្លៃមិនលើសពី ៨០ (ប៉ែតសិប) ភាគរយនៃថ្លៃទីផ្សារបច្ចុប្បន្នរបស់សញ្ញាបណ្ណនោះ។

៦- មូលបត្ររដ្ឋត្រូវវាយតម្លៃមិនលើសពី ៩០ (កៅសិប) ភាគរយនៃថ្លៃទីផ្សារបច្ចុប្បន្នរបស់មូលបត្ររដ្ឋនោះ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ ការអនុញ្ញាត អាចរាប់បញ្ចូលមូលបត្រផ្សេងទៀតដែលបានកាន់កាប់ជាទ្រព្យសកម្មរយៈពេលខ្លីបានតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១២.- ការកាត់បន្ថយលើទ្រព្យសកម្មរយៈពេលខ្លី**

ដើម្បីគណនាមូលធនសុទ្ធ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ ការអនុញ្ញាត ត្រូវកាត់បន្ថយពីទ្រព្យសកម្មរយៈពេលខ្លី នូវធាតុមួយចំនួនដូចខាងក្រោម÷

១- សំវិធានធនសម្រាប់បំណុលអាក្រក់ (Bad Debt)។ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ ការអនុញ្ញាតត្រូវផ្តល់ជូន **គ.ម.ក.** នូវគោលនយោបាយផ្ទៃក្នុងស្តីពីការគ្រប់គ្រងបំណុល និងការប៉ាន់ស្មានសំវិធានធនសម្រាប់បំណុលអាក្រក់ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីទទួលបានការអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។ នៅពេលមានការកែប្រែគោលនយោបាយនេះ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ ការអនុញ្ញាតត្រូវផ្តល់ជូន **គ.ម.ក.** នូវគោលនយោបាយថ្មី ដោយភ្ជាប់មកជាមួយនូវការ

បញ្ជាក់លើចំណុចដែលត្រូវបានកែប្រែក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីទទួលបានការអនុម័ត ដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។ **គ.ម.ក.** អាចពិនិត្យឡើងវិញនូវគោលនយោបាយនេះ និង តម្រូវឱ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតបង្កើនកម្រិតសំវិធានធនសម្រាប់បំណុលអាក្រក់។

២- ធាតុផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១៣.- ប្រតិបត្តិការមិនកត់ត្រា** (Off-Record Transactions)

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ត្រូវបង្ហាញរាល់ប្រតិបត្តិការមិនកត់ត្រានៅក្នុងបញ្ជីគណនេយ្យដល់ **គ.ម.ក.**។ អគ្គនាយកនៃ **គ.ម.ក.** មានឆន្ទានុសិទ្ធិកំណត់កម្រិតនៃការកាត់បន្ថយលើទ្រព្យសកម្មរយៈពេលខ្លីក្នុងការគណនាមូលធនសុទ្ធសម្រាប់ប្រតិបត្តិការមិនកត់ត្រា។

**ប្រការ ១៤.- ឆន្ទានុសិទ្ធិកែប្រែលក្ខខណ្ឌសម្រាប់គ្រប់គ្រងហានិភ័យ**

អគ្គនាយកនៃ **គ.ម.ក.** មានឆន្ទានុសិទ្ធិកែប្រែលក្ខខណ្ឌសម្រាប់គ្រប់គ្រងហានិភ័យណាមួយដូចមានចែងក្នុងប្រការ ១១ និងប្រការ ១២ នៃប្រកាសនេះ បន្ទាប់ពីវាយតម្លៃទៅតាមករណីនីមួយៗ។

**ប្រការ ១៥.- បំណុលសរុប**

បំណុលសរុបស្របតាមប្រកាសនេះរួមមាន÷

១- រាល់បំណុលទាំងអស់ស្របតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

២- បំណុលជាយថាហេតុទាំងអស់ ទោះបីជាបំណុលទាំងនោះមិនត្រូវបានបង្ហាញលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតក៏ដោយ។

៣- ធាតុផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

ធាតុដែលមិនត្រូវបានរាប់បញ្ចូលជាបំណុលសរុបរួមមាន÷

១- បំណុលបំពេញលើដើមទុន (Subordinated Loan) ដែលទទួលបានការអនុញ្ញាតអនុលោមតាមប្រការ ១៦ នៃប្រកាសនេះ។

២- សមតុល្យឥណពន្ធ និងសមតុល្យឥណទានដែលមានកិច្ចសន្យាកាត់កងគ្នាស្របច្បាប់ អាចត្រូវបានបន្សុតក្នុងការគណនាមូលធនសុទ្ធ។

៣- ធាតុផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

**ប្រការ ១៦.- បំណុលបំពេញលើដើមទុន**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត អាចដកបំណុលបំពេញលើដើមទុនចេញពីបំណុលបានលុះត្រាតែបានបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១- បំណុលបំពេញលើដើមទុននោះត្រូវមានរយៈពេលឥណប្រតិទានយ៉ាងតិច ២ (ពីរ) ឆ្នាំ។

២-ទំហំសរុបនៃបំណុលបំពេញលើដើមទុនទាំងអស់មិនត្រូវលើសពី ៥០(ហាសិប) ភាគរយនៃមូលធនភាគហ៊ុនិក។

៣-កិច្ចសន្យាបំណុលបំពេញលើដើមទុនត្រូវស្ថិតក្នុងទម្រង់ដែលភ្ជាប់លក្ខខណ្ឌមួយចំនួនដូចខាងក្រោម÷

ក- ឥណទាយកបំណុលបំពេញលើដើមទុនមិនត្រូវទាមទារ ឬទទួលពីក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត នូវការទូទាត់បំណុលបំពេញលើដើមទុនតាមរយៈការទូទាត់ជាសាច់ប្រាក់ ឬការកាត់កង ឬតាមវិធីសាស្ត្រផ្សេងទៀត រហូតដល់ឥណប្រតិទាន ឬរហូតរាល់ឥណទាយកផ្សេងទៀតទទួលបានការទូទាត់សង លើកលែងតែមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពី **គ.ម.ក.**។

ខ-ការទាមទារទូទាត់ដោយឥណទាយកបំណុលបំពេញលើដើមទុន ត្រូវស្ថិតនៅលំដាប់រងបន្ទាប់ពីការទាមទារទូទាត់ដោយឥណទាយកបំណុលផ្សេងទៀត។

គ- សិទ្ធិទទួលប្រាក់ដើម និងការប្រាក់ក្នុងអំឡុងពេលខ្ចីបំណុល ត្រូវស្ថិតនៅលំដាប់រងបន្ទាប់ពីឥណទាយកបំណុលផ្សេងទៀត។

ឃ-កាតព្វកិច្ចសងប្រាក់ដើម និងការប្រាក់នៃបំណុលបំពេញលើដើមទុន ត្រូវបានព្យួរ ក្នុងករណីអនុបាតមូលធនសុទ្ធរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ធ្លាក់ក្រោម ១៥០ (មួយរយហាសិប) ភាគរយ។

ង-ក្នុងស្ថានភាពជម្រះបញ្ជី ឬកែប្រែរចនាសម្ព័ន្ធរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ឥណទាយកបំណុលផ្សេងទៀតត្រូវមានសិទ្ធិទទួលបានការទូទាត់សងទាំងអស់ មុននឹងឥណទាយកបំណុលបំពេញលើដើមទុនអាចទទួលបានការទូទាត់សងចំពោះបំណុលបំពេញលើដើមទុន។

ច-កិច្ចសន្យាបំណុលបំពេញលើដើមទុនមិនត្រូវភ្ជាប់លក្ខខណ្ឌដែលអនុញ្ញាតឱ្យឥណទាយកបំណុលបំពេញលើដើមទុន ទាមទារការទូទាត់មុនដល់ឥណប្រតិទាន ឬពន្លឿនការសងបំណុលឡើយ។

ឆ-កិច្ចសន្យាបំណុលបំពេញលើដើមទុនមិនត្រូវភ្ជាប់លក្ខខណ្ឌចាប់បង្ខំសងរួម ឬលក្ខខណ្ឌហាមឃាត់ការខ្ចីប្រាក់បន្ថែម។

ជ-ការសងបំណុលទាំងអស់ ឬមួយផ្នែកនៃបំណុលបំពេញលើដើមទុន ត្រូវបានធ្វើឡើងតែនៅពេលមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី **គ.ម.ក.** ប៉ុណ្ណោះ។

**គ.ម.ក.** អាចកំណត់ទម្រង់កិច្ចសន្យាបំណុលបំពេញលើដើមទុនផ្សេងពីនេះ។

## ជំពូកទី ៥

## លក្ខខណ្ឌតម្រូវលើតម្រិតមូលធនសុទ្ធភាតព្វកិច្ច

### ប្រការ ១៧.- កម្រិតមូលធនសុទ្ធភាតព្វកិច្ច

កម្រិតមូលធនសុទ្ធកាតព្វកិច្ចរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត គឺជាចំនួនណាមួយដែលខ្ពស់ជាងគេរវាងចំណុចទី ១ និងចំណុចទី ២ ដូចខាងក្រោម÷

១-៥ (ប្រាំ) ភាគរយនៃមូលធនភាគហ៊ុនិក។

២-១០ (ដប់) ភាគរយនៃបំណុលសរុប។

### ប្រការ ១៨.- ឆន្ទានុសិទ្ធិកែប្រែកម្រិតមូលធនសុទ្ធកាតព្វកិច្ច

អគ្គនាយកនៃ **គ.ម.ក.** មានឆន្ទានុសិទ្ធិកែប្រែកម្រិតមូលធនសុទ្ធកាតព្វកិច្ច និងតម្រូវឱ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតបង្កើនមូលធនសុទ្ធដោយពិចារណាទៅលើកត្តាមួយចំនួនដូចខាងក្រោម÷

១-ទ្រព្យសកម្មដែលមានលក្ខណៈអសន្ទនីយភាព (Illiquidity)។

២-ព័ត៌មានហានិភ័យ (Risk profiles)។

៣-ហានិភ័យផ្សេងៗដែលក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតអាចជួបប្រទះ។

## ជំពូកទី ៦

## ភាតព្វកិច្ចផ្តល់របាយការណ៍ស្ថានភាពមូលធនសុទ្ធ

### ប្រការ ១៩.- របាយការណ៍មូលធនសុទ្ធប្រចាំថ្ងៃ

ក្រុមហ៊ុទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ត្រូវគណនាអនុបាតមូលធនសុទ្ធជាប្រចាំថ្ងៃ និងត្រូវរៀបចំនិងផ្ញើជូន **គ.ម.ក.** នូវរបាយការណ៍មូលធនសុទ្ធប្រចាំថ្ងៃក្នុងទម្រង់ និងតាមរយៈមធ្យោបាយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ក្នុងរយៈពេលយ៉ាងយូរត្រឹមថ្ងៃធ្វើការបន្ទាប់ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

### ប្រការ ២០.- របាយការណ៍មូលធនសុទ្ធប្រចាំខែ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ត្រូវផ្តល់ជូន **គ.ម.ក.** យ៉ាងយូរត្រឹមថ្ងៃទី១០ នៃខែបន្ទាប់ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** នូវរបាយការណ៍ប្រចាំខែដូចខាងក្រោម÷

១-របាយការណ៍តុល្យភាពសាកល្បងសង្ខេប (Trial Balance in summary)។

២-របាយការណ៍សន្ទនីយភាព (Liquidity Statement) ក្នុងទម្រង់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

### ប្រការ ២១.- ឆន្ទានុសិទ្ធិតម្រូវឱ្យគណនា និងធ្វើរបាយការណ៍ស្ថានភាពមូលធនសុទ្ធ

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើការគណនា និងធ្វើរបាយការណ៍ស្ថានភាពមូលធនសុទ្ធ និងកម្រិតមូលធនសុទ្ធកាតព្វកិច្ចគ្រប់ពេលវេលាទៅតាមការចាំបាច់។

### ប្រការ ២២.- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ត្រូវផ្តល់ជូន **គ.ម.ក.** នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលត្រូវបានធ្វើសវនកម្មរួចដោយក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ខែ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធនីមួយៗ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ។

ករណីកាលបរិច្ឆេទដូចមានចែងក្នុងប្រការ ១៩ និងប្រការ ២០ នៃប្រកាសនេះ និងកថាខណ្ឌទី ១ នៃប្រការនេះ ត្រូវចំថ្ងៃចុងសប្តាហ៍ ឬថ្ងៃឈប់សម្រាកសាធារណៈ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវបានអនុញ្ញាតឱ្យផ្តល់របាយការណ៍ទាំងអស់នៅថ្ងៃធ្វើការបន្ទាប់។

### ប្រការ ២៣.- ការយកចិត្តទុកដាក់ក្នុងការរៀបចំរបាយការណ៍

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ត្រូវរៀបចំរបាយការណ៍ និងព័ត៌មានអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យ និងប្រកាសនេះ ដោយប្រុងប្រយ័ត្ន និងដោយយកចិត្តទុកដាក់ ដើម្បីធានាឱ្យបាននូវភាពសុក្រឹតច្បាស់លាស់ និងពេញលេញ។ ប្រសិនមានកំហុសឆ្គង ឬការខ្វះខាតណាមួយត្រូវបានរកឃើញ បុគ្គលដែលបានផ្តល់របាយការណ៍នោះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ក.** ជាបន្ទាន់ និងត្រូវផ្តល់សារជាថ្មីនូវរបាយការណ៍ និងព័ត៌មានដែលកែតម្រូវរួច។

## ជំពូកទី ៧
## វិធានការកែតម្រូវបន្ទាន់

### ប្រការ ២៤.- អនុសាសន៍ពាក់ព័ន្ធនឹងការគ្រប់គ្រង

ករណីអនុបាតមូលធនសុទ្ធនៃក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ធ្លាក់ក្រោម ១៥០ (មួយរយហាសិប) ភាគរយ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវចាត់វិធានការកែតម្រូវបន្ទាន់តាមអនុសាសន៍របស់អគ្គនាយកនៃ **គ.ម.ក.**។

វិធានការកែតម្រូវបន្ទាន់ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ សំដៅដល់វិធានការណាមួយ ឬទាំងស្រុងដូចខាងក្រោម÷

១- ពង្រឹងធនធានមនុស្ស និងការគ្រប់គ្រងស្ថាប័ន។

២- កាត់បន្ថយចំណាយ។

៣- ដាក់កម្រិតលើសកម្មភាពនានាដែលនាំឱ្យមានការធ្លាក់ចុះអនុបាតមូលធនសុទ្ធ។

**ប្រការ ២៥.- ការតម្រូវពង្រឹងការគ្រប់គ្រង**

ករណីអនុបាតមូលធនសុទ្ធនៃក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ធ្លាក់ក្រោម ១២០(មួយរយម្ភៃ) ភាគរយ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវចាត់វិធានការកែតម្រូវបន្ទាន់តាមការតម្រូវរបស់អគ្គនាយកនៃ **គ.ម.ភ.**។

វិធានការកែតម្រូវបន្ទាន់ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ សំដៅដល់វិធានការណាមួយ ឬទាំងស្រុងដូចខាងក្រោម÷

១-ដាក់កម្រិតលើការកាន់កាប់ទ្រព្យសកម្មដែលមានហានិភ័យខ្ពស់ និងការលក់ ឬដោះដូរទ្រព្យសកម្ម (Disposition of Asset)។

២-បិទ និងបង្រួមបញ្ចូលគ្នានូវការិយាល័យអាជីវកម្ម ឬការដាក់កម្រិតលើការបើកការិយាល័យអាជីវកម្មថ្មី។

៣-ទាមទារឱ្យមានការផ្លាស់ប្ដូរបុគ្គលិក។

៤-វិធានការដូចមានចែងក្នុងកថាខណ្ឌទី ២ នៃប្រការ ២៤ នៃប្រកាសនេះ។

**ប្រការ ២៦.- ការបញ្ជាពង្រឹងការគ្រប់គ្រង**

ករណីអនុបាតមូលធនសុទ្ធនៃក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ធ្លាក់ក្រោម ១០០(មួយរយ) ភាគរយ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវចាត់វិធានការកែតម្រូវបន្ទាន់តាមការបញ្ជារបស់អគ្គនាយកនៃ **គ.ម.ភ.**។

វិធានការកែតម្រូវបន្ទាន់ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ សំដៅដល់វិធានការណាមួយ ឬទាំងស្រុងដូចខាងក្រោម÷

១-មិនបង្កើន ឬកាត់បន្ថយភ្លាមៗនូវសកម្មភាពជួញដូរឧបករណ៍និស្សន្ទ ឬសកម្មភាពហិរញ្ញប្បទាន។

២-បន្តប្រតិបត្តិការអាជីវកម្មទៅតាមលក្ខខណ្ឌដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ភ.**។

៣-វិធានការដូចមានចែងក្នុងកថាខណ្ឌទី ២ នៃប្រការ ២៥ នៃប្រកាសនេះ។

ករណីក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតនៅតែមិនអាចបំពេញបាននូវអនុបាតមូលធនសុទ្ធដូចមានកំណត់ក្នុងកថាខណ្ឌទី ២ នៃប្រការ ៨ នៃប្រកាសនេះ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវបានចាត់ទុកថាមានបញ្ហាហិរញ្ញវត្ថុ និងត្រូវចាប់ផ្ដើមអនុវត្តនីតិវិធីបន្តដូចមានបញ្ញត្តិក្នុងអនុក្រឹត្យស្ដីពីបុននីតិសម្បទា និងការជម្រះបញ្ជីក្នុងវិស័យមូលបត្រ។

**ប្រការ ២៧.- ការផ្ដល់នូវមូលហេតុក្នុងការចាត់វិធានការ**

អគ្គនាយកនៃ **គ.ម.ភ.** ត្រូវមានមូលដ្ឋាន និងផ្ដល់នូវមូលហេតុក្នុងការចាត់វិធានការដូចមានចែងក្នុងប្រការ ២៤, ប្រការ ២៥ និងប្រការ ២៦ នៃប្រកាសនេះ ដល់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដែលទទួលរងវិធានការកែតម្រូវបន្ទាន់។

### ប្រការ ២៨.- ការលើកលែងជាបណ្តោះអាសន្នចំពោះវិធានការកែតម្រូវបន្ទាន់

ទោះបីជាក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតស្ថិតក្នុងស្ថានភាពដូចកំណត់ក្នុងកថាខណ្ឌទី ១ នៃប្រការ ២៤, កថាខណ្ឌទី ១ នៃប្រការ ២៥ ឬកថាខណ្ឌទី ១ នៃប្រការ ២៦ នៃប្រកាសនេះក៏ដោយ អគ្គនាយកនៃ **គ.ម.ភ.** អាចលើកលែងជាបណ្តោះអាសន្ននូវវិធានការកែតម្រូវបន្ទាន់ក្នុងរយៈពេលជាក់លាក់មួយ ក្នុងករណីក្រុមហ៊ុននោះត្រូវបានវាយតម្លៃថានឹងមិនធ្លាក់ក្នុងស្ថានភាពដែលតម្រូវឱ្យចាត់វិធានការកែតម្រូវបន្ទាន់ ដោយសារការបង្កើនដើមទុន ឬលក់ចេញនូវទ្រព្យសកម្មរបស់ខ្លួនជាដើម។

### ប្រការ ២៩.- ផែនការពង្រឹងការគ្រប់គ្រង

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដែលបានទទួលអនុសាសន៍ ការតម្រូវ ឬការបញ្ជាពង្រឹងការគ្រប់គ្រងដូចមានចែងក្នុងប្រការ ២៤, ប្រការ ២៥ ឬប្រការ ២៦ នៃប្រកាសនេះ ត្រូវរៀបចំផែនការពង្រឹងការគ្រប់គ្រងដែលមានមាតិកា និងខ្លឹមសារឆ្លុះបញ្ចាំងការពង្រឹងការគ្រប់គ្រងស្របតាមអនុសាសន៍ ការតម្រូវ ឬការបញ្ជាដែលទទួលបាន និងត្រូវដាក់ជូនអគ្គនាយកនៃ **គ.ម.ភ.** ដើម្បីសម្រេចក្នុងរយៈពេល ១ (មួយ) ខែ គិតចាប់ពីកាលបរិច្ឆេទទទួលបានអនុសាសន៍ ការតម្រូវ ឬការបញ្ជាពង្រឹងការគ្រប់គ្រងនោះ ឬក្នុងរយៈពេលជាក់លាក់មួយកំណត់ដោយអគ្គនាយកនៃ **គ.ម.ភ.**។

អគ្គនាយកនៃ **គ.ម.ភ.** ត្រូវសម្រេចលើផែនការពង្រឹងការគ្រប់គ្រងដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ១ (មួយ) ខែ គិតចាប់ពីកាលបរិច្ឆេទទទួលបានផែនការពង្រឹងការគ្រប់គ្រងនោះ។

ករណីផែនការពង្រឹងការគ្រប់គ្រងមិនមានលក្ខណៈសមស្របតាមអនុសាសន៍ ការតម្រូវ ឬការបញ្ជាពង្រឹងការគ្រប់គ្រង ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវដាក់ជូន **គ.ម.ភ.** ឡើងវិញនូវផែនការពង្រឹងការគ្រប់គ្រងតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ភ.**។

### ប្រការ ៣០.- រយៈពេលអនុវត្តផែនការពង្រឹងការគ្រប់គ្រង

រយៈពេលអនុវត្តផែនការពង្រឹងការគ្រប់គ្រងត្រូវកំណត់ដូចខាងក្រោម÷

១-រយៈពេល ៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទសម្រេចលើផែនការពង្រឹងការគ្រប់គ្រងតាមអនុសាសន៍ពង្រឹងការគ្រប់គ្រង។

២-រយៈពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទសម្រេចលើផែនការពង្រឹងការគ្រប់គ្រងតាមការតម្រូវពង្រឹងការគ្រប់គ្រង។

៣-រយៈពេលអនុវត្តផែនការពង្រឹងការគ្រប់គ្រងតាមការបញ្ជាពង្រឹងការគ្រប់គ្រង ត្រូវកំណត់ដោយអគ្គនាយកនៃ **គ.ម.ភ.**។

ករណីក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតបានទទួលអនុសាសន៍ពង្រឹងការគ្រប់គ្រងស្របតាមប្រការ ២៤ នៃប្រកាសនេះ ហើយក្នុងពេលកំពុងអនុវត្តផែនការពង្រឹងការគ្រប់គ្រង ក្រុមហ៊ុននោះបានទទួល

ការតម្រូវពង្រឹងការគ្រប់គ្រងបន្ថែមទៀត រយៈពេលអនុវត្តផែនការពង្រឹងការគ្រប់គ្រងមិនត្រូវលើសពី ១ (មួយ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទសម្រេចលើផែនការពង្រឹងការគ្រប់គ្រងតាមអនុសាសន៍ដែលទទួលបាន។

**ប្រការ ៣១.- ការកែប្រែនៃផែនការពង្រឹងការគ្រប់គ្រង**

ករណីផែនការពង្រឹងការគ្រប់គ្រងមិនបានសម្រេចតាមគោលដៅគ្រោងទុក ឬមានការលំបាកក្នុងការអនុវត្តតាមផែនការពង្រឹងការគ្រប់គ្រង ដោយសារមានការប្រែប្រួលបរិយាកាសអាជីវកម្ម ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតអាចស្នើសុំការអនុញ្ញាតមកអគ្គនាយកនៃ **គ.ម.ក.** ដើម្បីកែប្រែមាតិកា និងខ្លឹមសារនៃផែនការពង្រឹងការគ្រប់គ្រង ដោយភ្ជាប់មកជាមួយនូវផែនការពង្រឹងការគ្រប់គ្រងថ្មី។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងអំពីការសម្រេចទទួលយកសំណើកែប្រែមាតិកា និងខ្លឹមសារនៃផែនការពង្រឹងការគ្រប់គ្រង បន្ទាប់ពីវាយតម្លៃទៅតាមករណីនីមួយៗ។ បញ្ញត្តិចែងក្នុងកថាខណ្ឌទី ៣ នៃប្រការ ២៩ នៃប្រកាសនេះ ត្រូវអនុវត្តដូចគ្នាចំពោះក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ដែលស្នើសុំកែប្រែមាតិកា និងខ្លឹមសារនៃផែនការពង្រឹងការគ្រប់គ្រងស្របតាមកថាខណ្ឌទី ១ នៃប្រការនេះ។

**ប្រការ ៣២.- របាយការណ៍លទ្ធផលនៃការអនុវត្តផែនការពង្រឹងការគ្រប់គ្រង**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដែលបានទទួលការសម្រេចលើផែនការពង្រឹងការគ្រប់គ្រងស្របតាមប្រការ ២៩ នៃប្រកាសនេះ ត្រូវដាក់ជូន **គ.ម.ក.** នូវលទ្ធផលអនុវត្តផែនការពង្រឹងការគ្រប់គ្រងប្រចាំខែក្នុងរយៈពេលមិនលើសពីថ្ងៃទី ១០ (ដប់) នៃខែបន្ទាប់ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដែលបានអនុវត្តផែនការពង្រឹងការគ្រប់គ្រង ត្រូវដាក់ជូន **គ.ម.ក.** នូវលទ្ធផលអនុវត្តផែនការពង្រឹងការគ្រប់គ្រងក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីរយៈពេលនៃការអនុវត្តផែនការនោះបានបញ្ចប់ដូចកំណត់ក្នុងប្រការ ៣០ នៃប្រកាសនេះ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៣៣.- ការសម្រេចបញ្ចប់វិធានការកែតម្រូវបន្ទាន់**

ក្នុងអំឡុងពេលនៃការអនុវត្តផែនការពង្រឹងការគ្រប់គ្រង ករណីក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដែលបានទទួលអនុសាសន៍ ការតម្រូវ ឬការបញ្ជាពង្រឹងការគ្រប់គ្រង រក្សាបានឡើងវិញនូវអនុបាតមូលធនសុទ្ធយ៉ាងតិច ១៥០ (មួយរយហាសិប) ភាគរយ អគ្គនាយកនៃ **គ.ម.ក.** អាចពិចារណាសម្រេចបញ្ចប់វិធានការកែតម្រូវបន្ទាន់។

## ជំពូកទី ៨

## ទោសប្បញ្ញត្តិ

**ប្រការ ៣៤.- ពិន័យអន្តរការណ៍**

ដោយមិនគិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញតិជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដែលប្រព្រឹត្តល្មើសនឹងប្រការ ៦ ឬមិនគោរពតាមសេចក្តីណែនាំ ឬតាមការកំណត់ ឬតាមការតម្រូវរបស់អគ្គនាយកនៃ **គ.ម.ក.** ឬមិនអនុវត្តតាមវិធានការទណ្ឌកម្មរដ្ឋបាលណាមួយរបស់ **គ.ម.ក.** ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់មិនលើសពី ២០០.០០០.០០០(ពីររយលាន) រៀល និង/ឬទណ្ឌកម្មរដ្ឋបាលផ្សេងទៀតដូចមានចែងក្នុងប្រការ ៣៥ នៃប្រកាសនេះ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដែលយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ដូចមានកំណត់នៅក្នុងប្រការ ១៩, ប្រការ ២០ និងប្រការ ២២ នៃប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី **គ.ម.ក.** ដូចខាងក្រោម÷

១-ចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុងមួយថ្ងៃ ចំពោះការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំ។

២-ចំនួន ៤០០.០០០ (បួនរយពាន់) រៀល ក្នុងមួយថ្ងៃ ចំពោះការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ប្រចាំថ្ងៃ។

ក្នុងករណីមិនរាលចាល បុគ្គលប្រព្រឹត្តល្មើសត្រូវទទួលពិន័យអន្តរការណ៍ទ្វេរដង។

ក្នុងករណីការប្រព្រឹត្តល្មើសបានបង្កឱ្យមានព្យសនកម្ម បុគ្គលប្រព្រឹត្តល្មើសត្រូវទទួលរងពិន័យអន្តរការណ៍ពី **គ.ម.ក.** និង/ឬជួសជុលសំណងព្យសនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

មុននឹងចាត់វិធានដូចមានចែងក្នុងកថាខណ្ឌទី ១ ឬកថាខណ្ឌទី ២ នៃប្រការនេះ អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តល់ឱកាសឱ្យបុគ្គលប្រព្រឹត្តល្មើសធ្វើការស្រាយបំភ្លឺជាមុនសិន។

**ប្រការ ៣៥.- ទណ្ឌកម្មរដ្ឋបាល**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដែលប្រព្រឹត្តល្មើសនឹងប្រការ ៤, ប្រការ ៥, ប្រការ ៧, ប្រការ ៨, ប្រការ ៩, ប្រការ ១២, ប្រការ ១៥, ប្រការ ១៨, ប្រការ ២១, ប្រការ ២៣, ប្រការ ២៤, ប្រការ ២៥, ប្រការ ២៦, កថាខណ្ឌទី ១ និងកថាខណ្ឌទី ៣ នៃប្រការ ២៩ និងប្រការ ៣២ នៃប្រកាសនេះត្រូវទទួលទណ្ឌកម្មរដ្ឋបាលពី **គ.ម.ក.** តាមកថាខណ្ឌទី ២ នៃប្រការនេះ។

អគ្គនាយកនៃ **គ.ម.ក.** អាចដាក់ទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

១-ការព្រមាន ឬដាស់តឿន។

២-ការដឹកនាំកែតម្រង់។

៣-ការតម្រូវលើការបណ្តេញចេញអភិបាល និង/ឬបុគ្គលិកជាន់ខ្ពស់។

៤-ការដាក់កំហិតលើអាជ្ញាបណ្ណ/ការអនុញ្ញាត។

៥-ការព្យួរអាជ្ញាបណ្ណ/ការអនុញ្ញាត។

៦-ការដកហូតអាជ្ញាបណ្ណ/ការអនុញ្ញាត។

មុននឹងចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី ២ នៃប្រការនេះ អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តល់ឱកាសឱ្យបុគ្គលប្រព្រឹត្តល្មើសធ្វើការស្រាយបំភ្លឺជាមុនសិន។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

### ប្រការ ៣៦.- គោលការណ៍ណែនាំ

អគ្គនាយកនៃ **គ.ម.ក.** អាចចេញគោលការណ៍ណែនាំអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមប្រកាសនេះ។

### ប្រការ ៣៧.- ការអនុវត្ត

អគ្គនាយកនៃ **គ.ម.ក.** ប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត គ្រប់ប្រធាននាយកដ្ឋាន-អង្គភាពស្ថិតនៅចំណុះឱ្យ **គ.ម.ក.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ ធ្នូ ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣៧
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ